**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តមណ្ឌលគិរី**

លេខ:០៧៦/១៦ ខេម.ស៊ល

មណ្ឌលគិរីថ្ងៃទី,..០៨.....ខែ..៣....ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៧

អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី សូមជម្រាបជូនលោក លោកស្រីអ្នកទទួលការជ្រាបថាៈ ខេត្ត នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧។ អ្នកទទួល ការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំង អស់ នូវទូទាំងព្រះរាជាណាចក្រកម្ពុជា ។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១៖ អ្នកទទួលការសំណង់ទូទៅ(ការងារសំណង់អគារ និងការងារបេតុង....។ល។)
- ប្រភេទទី២៖ អ្នកទទួលការការងារដី(ប្រឡាយ ទំនប់ ផ្លូវដី ផ្លូវក្រួសក្រហម........។ល។)
- ប្រភេទទី៣៖អ្នកទទួលការឯកទេស(អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេស សម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់.......។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំ ចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទ ពិសោធន៍អនុវត្តគម្រោងទាក់ទងទៅនិងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាព ការងារបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើល គុណភាពការងារ ភាពស្មោះត្រង់ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការ ជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក ។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេ លក្ខណសម្បត្តិ នឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងសំរេច។ អ្នកទទួលការទាំងឡាយណាដែលត្រូវបានរក ឃើញមានការពាក់ព័ន្ធនឹងការឃុបឃិតសមគំនិតគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវ បានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះនឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នក ទទួលការឡើយ ។

អាស្រ័យហេតុនេះ បើលោក លោកស្រី អ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាក់ការផែនការនិងវិនិយោគ នៃសាលាខេត្តមណ្ឌលគិរី ចាប់ពីថ្ងៃជូនដំណឹងនេះ ***រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១៧.០០នាទី*** ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាក់ការផែនការនឹងវិនិយោគដោយឥតបង់ថ្លៃដែលមានទីតាំងស្ថិតនៅសាលាខេត្តមណ្ឌលគិរី ឬអាចទាញយកពីគេហទំព័ររបស់ គ.ជ.អ.ប ។

**អភិបាលខេត្ត**

**ស្វាយ សំអ៊ាង**